# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសំរួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និង ប្រាក់កំរៃគរុកោសល្យក្នុងវិស័យអប់រំ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សំរេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះ មានគោលដៅបំពេញបន្ថែមព្រះរាជក្រឹត្យ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស ដូចមានចែងក្នុងជំពូកទី២ ស្តីពីប្រាក់បំណាច់មុខងារ។

www.pheakdeylaw.com

**មាត្រា ២.-**

អនុក្រឹត្យនេះ កំណត់ការកែប្រែប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការដែលមានមុខតំណែងជា ប្រធាននាយកដ្ឋាន អភិបាលរងខេត្ត-ក្រុង អធិការថ្នាក់កណ្ដាល ព្រឹទ្ធបុរសមហាវិទ្យាល័យ អភិបាលស្រុក-ខ័ណ្ឌ ហើយដែលស្ថិតនៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង-ស្ថាប័ន និងកំណត់បន្ថែម ប្រាក់កំរៃគរុកោសល្យរបស់មន្ត្រីរាជការ ក្នុងវិស័យអប់រំ ។

## ជំពូកទី ២

## ប្រាក់បំណាច់មុខងារ

**មាត្រា ៣.-**

មន្ត្រីរាជការស៊ីវិល ដែលមានមុខតំណែងជា ប្រធាននាយកដ្ឋាន អភិបាលរងខេត្ត-ក្រុង អធិការថ្នាក់កណ្ដាល ព្រឹទ្ធបុរសមហាវិទ្យាល័យ អភិបាលស្រុក-ខ័ណ្ឌ ហើយដែលស្ថិតនៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង-ស្ថាប័នថ្នាក់កណ្ដាល ត្រូវបានទទួលប្រាក់បំណាច់មុខងារប្រចាំខែ ដូចមានចែងនៅក្នុងតារាងខាងក្រោមនេះ :

| ល.រ | មុខងារ | កាំរិត ទី៥ | កាំរិត ទី៤ | កាំរិត ទី៣ | កាំរិត ទី២ | កាំរិត ទី១ |
|---|---|---|---|---|---|---|
| ១ | ប្រធាននាយកដ្ឋាន | ៦២០ ០០០ ៛ | ៦៥៨ ០០០ ៛ | ៦៩៨ ០០០ ៛ | ៧៤១ ០០០ ៛ | ៧៨៦ ០០០ ៛ |
| ២ | អភិបាលរង ខេត្ត-ក្រុង | ៦១៥ ០០០ ៛ | ៦៥៣ ០០០ ៛ | ៦៩៣ ០០០ ៛ | ៧៣៦ ០០០ ៛ | ៧៨១ ០០០ ៛ |
| ៣ | អធិការថ្នាក់កណ្ដាល | ៦១០ ០០០ ៛ | ៦៤៨ ០០០ ៛ | ៦៨៨ ០០០ ៛ | ៧៣១ ០០០ ៛ | ៧៧៦ ០០០ ៛ |
| ៤ | ព្រឹទ្ធបុរសមហាវិទ្យាល័យ | ៦០៥ ០០០ ៛ | ៦៤៣ ០០០ ៛ | ៦៨៣ ០០០ ៛ | ៧២៦ ០០០ ៛ | ៧៧១ ០០០ ៛ |
| ៥ | អភិបាល ស្រុក-ខ័ណ្ឌ | ៥០០ ០០០ ៛ | ៥៣៨ ០០០ ៛ | ៥៧៨ ០០០ ៛ | ៦២១ ០០០ ៛ | ៦៦៦ ០០០ ៛ |

**មាត្រា ៤.-**

ប្រធានអង្គភាព ដែលមានរចនាសម្ព័ន្ធក្នុងក្រសួង-ស្ថាប័ន និងស្មើនាយកដ្ឋាន ត្រូវទទួលបានប្រាក់បំណាច់មុខងារជាប្រធាននាយកដ្ឋាន ដូចមានចែងនៅក្នុងមាត្រា ៣ ។

## ជំពូកទី ៣

## ប្រាក់កំរៃគរុកោសល្យ

**មាត្រា ៥.-**

ប្រាក់កំរៃគរុកោសល្យ គឺជាប្រាក់បន្ថែមលើប្រាក់បំណាច់មុខងារប្រចាំខែ ដែលត្រូវផ្ដល់ជូនមន្ត្រីរាជការក្នុងវិស័យអប់រំ ហើយដែលបានឆ្លងកាត់ វគ្គបណ្ដុះបណ្ដាលគរុកោសល្យ ។



www.pheakdeylaw.com

មាត្រា ៦.-

ប្រាក់កំរៃគរុកោសល្យ ត្រូវផ្តល់ជូនទៅតាមក្របខ័ណ្ឌប្រភេទមន្ត្រីរាជការ ដូចខាងក្រោម :

| ល.រ | ក្របខ័ណ្ឌ | ប្រាក់កំរៃគរុកោសល្យ |
|---|---|---|
| ១ | ប្រភេទ ក | ១២ ០០០៛ |
| ២ | ប្រភេទ ខ | ១០ ០០០៛ |
| ៣ | ប្រភេទ គ | ៨ ០០០៛ |
| ៤ | ប្រភេទ ឃ | ៦ ០០០៛ |

មាត្រា ៧.-

ការកែប្រែប្រាក់កំរៃគរុកោសល្យ ត្រូវធ្វើឡើងដោយអនុក្រឹត្យ ។

មាត្រា ៨.-

មន្ត្រីរាជការឯកទេសផ្សេងៗ ដែលត្រូវបានឧទ្ទេសនាមដោយក្រសួង ស្ថាប័ន អោយបង្ហាត់បង្រៀនពេញពេលនៅតាមគ្រឹះស្ថានសិក្សានានារយៈពេលពេញ ១ឆ្នាំ ត្រូវទទួលបានប្រាក់កំរៃគរុកោសល្យ ។

លិខិតឧទ្ទេសនាម ត្រូវធ្វើឡើង ១ឆ្នាំម្តងៗ ។

## ជំពូកទី ៤

## ប្រាក់បង្គ្រប់

មាត្រា ៩.-

មន្ត្រីរាជការដែលទទួលបានប្រាក់បៀវត្សថ្មី (បៀវត្សមូលដ្ឋាន និងប្រាក់បំណាច់មុខងារ) ទាបជាងប្រាក់បៀវត្សចាស់ ត្រូវទទួលបានប្រាក់បង្គ្រប់ ដែលធានាមិនអោយទាបជាងប្រាក់បៀវត្សចាស់ ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

មាត្រា ១០.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។



www.pheakdeylaw.com

មាត្រា ១១.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន។

មាត្រា ១២.-

អនុក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០២ តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

ប្រធានឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ

**ហ៊ុន សែន**

បានយកសេចក្ដីជំរាបជូន

សម្ដេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**និងប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល**

**សុខ អាន**

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១១
-ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com